សន្លឹកព័ត៌មានស្ដីពីថ្នាំវ៉ាក់សាំង

# ការប្រើវ៉ាក់សាំងហ្សូស្ទ័ររួមគ្នា (រើម)៖ *តើលោកអ្នកត្រូវដឹងអ្វីខ្លះ*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សេចក្ដីថ្លែងការណ៍នៃព័ត៌មានអំពីថ្នាំវ៉ាក់សាំងជាច្រើនគឺ អាចរកបានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ ចូលមើល www.immunize.org/vis

## 1. ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

**ថ្នាំវ៉ាក់សាំងហ្សូស្ទ័ររួមគ្នា (រើម)** អាចបង្ការ **ជំងឺរើម**។

**រើម** (ត្រូវបានគេហៅថាហឺពហ្សូស្ទ័រ ឬហៅថារើម) គឺជាកន្ទួលលើស្បែកឈឺចាប់ខ្លាំងមួយ ដែលមានពងបែក។ លើសពីកន្ទួលរមាស់ ជំងឺរើមអាចបណ្ដាលឱ្យក្ដៅខ្លួន ឈឺក្បាល ញាក់ ឬឈឺក្រពះ។ ការឆ្លងរើមមិនងាយបង្កទៅជាបញ្ហាស្មុគស្មាញដូចជាជំងឺរលាកសួត បញ្ហាត្រចៀក ងងឹតភ្នែក រលាកខួក្បាល (រលាកស្រោមខួក្បាល) ឬដល់ស្លាប់ទេ។



ហានិភ័យនៃជំងឺរើមកើនឡើងតាមអាយុ។ ផលវិបាកទូទៅបំផុតនៃជំងឺរើមគឺការឈឺចាប់សរសៃប្រសាទរយៈពេលវែងហៅថា postherpetic neuralgia (PHN) ។ PHN កើតឡើងនៅកន្លែងដែលមានកន្ទួលរមាស់ ហើយអាចមានរយៈពេល ជាច្រើនខែ ឬច្រើនឆ្នាំបន្ទាប់ពីកន្ទួលនោះបាត់។ ការឈឺចាប់ពី PHN អាចធ្ងន់ធ្ងរ និងចុះខ្សោយ។

ហានិភ័យនៃ PHN ឡើងតាមអាយុ។ មនុស្សវ័យចំណាស់ដែលមានជំងឺរើមទំនងជាវិវត្តទៅជា PHN ហើយមានការឈឺចាប់យូរអង្វែង និងធ្ងន់ធ្ងរជាងមនុស្សវ័យក្មេង។

អ្នកដែលមានប្រព័ន្ធការពាររាងកាយចុះខ្សោយ ក៏មានហានិភ័យខ្ពស់នៃការកើត ជំងឺរើម និងផលវិបាកពីជំងឺនេះផងដែរ។

រើមបង្កឡើងដោយវីរុស វ៉ារីសេឡា ហ្សូស្ទ័រ ដូចគ្នានឹងវីរុសដែលបង្កជំងឺអុតស្វាយ។ បន្ទាប់ពីអ្នកកើតជំងឺអុតស្វាយ វីរុសនោះនឹងសង្ងំនៅក្នុងខ្លួនរបស់អ្នក ហើយអាច បង្កជារើមនៅពេលក្រោយ។ ជំងឺរើមមិនអាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបានទេ ប៉ុន្តែមេរោគដែល បណ្ដាលឱ្យកើតជំងឺរើមអាចរីករាលដាល និងបង្កជំងឺអុតស្វាយចំពោះអ្នកដែល មិនធ្លាប់កើតជំងឺអុតស្វាយ ឬមិនធ្លាប់ទទួលថ្នាំបង្ការជំងឺអុតស្វាយ។

## 2. វ៉ាក់សាំងការពាររើម (ការប្រើរួមគ្នា)

ថ្នាំវ៉ាក់សាំងការពារជំងឺរើមរួមគ្នា ផ្ដល់នូវការការពារដ៏រឹងមាំប្រឆាំងនឹងជំងឺរើម។ តាមរយៈការការពារជំងឺរើម ថ្នាំវ៉ាក់សាំងការពារជំងឺរើមរួមគ្នា ក៏អាចការពារ ប្រឆាំងនឹង PHN និងផលវិបាកផ្សេងៗទៀតផងដែរ។

ថ្នាំវ៉ាក់សាំងការពារជំងឺរើមរួមគ្នា ត្រូវបានណែនាំឱ្យប្រើសម្រាប់មនុស្សដូចតទៅ៖

- **មនុស្សចាស់អាយុ 50 ឆ្នាំ ឬ ចាស់ជាងនេះ**
- **មនុស្សធំដែលមានអាយុចាប់ពី 19 ឆ្នាំឡើងទៅដែលមានប្រព័ន្ធការពារ រាងកាយចុះខ្សោយ** ដោយសារជំងឺ ឬការព្យាបាល

ថ្នាំវ៉ាក់សាំងជំងឺរើមត្រូវបានផ្ដល់ជាស៊េរីពីរដូស។ សម្រាប់មនុស្សភាគច្រើន ដូសទីពីរគួរត្រូវបានផ្ដល់ឱ្យពី 2 ទៅ 6 ខែ បន្ទាប់ពីទទួលដូសដំបូង។ មនុស្សមួយចំនួនដែលមាន ឬនឹងមានប្រព័ន្ធភាពស៊ាំចុះខ្សោយអាចទទួល វ៉ាក់សាំងដូសទីពីររយៈពេល 1 ខែ ទៅ 2 ខែ បន្ទាប់ពីចាក់វ៉ាក់សាំងដូសដំបូង។ សូមសួរអ្នកផ្ដល់សេវាថែទាំសុខភាពរបស់លោកអ្នកសម្រាប់ជាការណែនាំ។

អ្នកដែលធ្លាប់មានជំងឺរើមពីមុន និងអ្នកដែលបានទទួលវ៉ាក់សាំងវ៉ារីសែឡា (ជំងឺអុតស្វាយ) ត្រូវបានណែនាំអោយទទួលថ្នាំបង្ការជំងឺរើមរួមគ្នា។ វ៉ាក់សាំងនេះក៏ត្រូវបានគេណែនាំសម្រាប់មនុស្សដែលចាក់វ៉ាក់សាំងការពារជំងឺរើមរស់រួចហើយ វ៉ាក់សាំងការពារជំងឺរើមរស់។ មិនមានមេរោគរស់នៅក្នុងវ៉ាក់សាំងការពារជំងឺរើមរួមគ្នាទេ។

ថ្នាំវ៉ាក់សាំងជំងឺរើមអាចចាក់ឲ្យក្នុងពេលដំណាលគ្នានឹងថ្នាំវ៉ាក់សាំងដទៃទៀត។

U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 3. និយាយជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកដើម្បីស្វែងយល់បន្ថែមទៀត

ប្រាប់អ្នកផ្តល់វ៉ាក់សាំងរបស់អ្នក ប្រសិនបើបុគ្គលនោះទទួលវ៉ាក់សាំង៖

- មាន **ប្រតិកម្មអាឡែហ្សីបន្ទាប់ពីការទទួលវ៉ាក់សាំងការពារជំងឺរើមរួមគ្នា** ឬមាន **អាឡែហ្សីធ្ងន់ធ្ងរ គម្រាមកំហែងដល់ជីវិត**
- **កំពុងជួបប្រទះស្ថានភាពនៃកើតជំងឺរើម**
- **កំពុងមានផ្ទៃពោះ**

ក្នុងករណីខ្លះ អ្នកផ្តល់សេវាថែទាំ សុខភាពរបស់កូនអ្នកអាចសម្រេចចិត្តពន្យារពេលការចាក់វ៉ាក់សាំងជំងឺរើម រហូតដល់ការណាត់ជួបនាពេលខាងមុខ។

អ្នកដែលមានជំងឺស្រាល ដូចជាជំងឺផ្តាសាយ អាចទទួលថ្នាំបង្ការនេះបាន។ អ្នកដែលមានជំងឺធ្ងន់ល្មម ឬធ្ងន់ធ្ងរ គួររង់ចាំរហូតដល់ពួកគេជាសះស្បើយសិន មុនពេលទទួលថ្នាំវ៉ាក់សាំងជំងឺរើម។

អ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នកអាចផ្តល់ព័ត៌មានបន្ថែមដល់លោកអ្នកបាន។

## 4. ហានិភ័យកើតប្រតិកម្មថ្នាំវ៉ាក់សាំង

- ជាធម្មតា អការៈការឈឺដៃជាមួយនឹងការឈឺចាប់ស្រាល ឬមធ្យម បន្ទាប់ពី ចាក់វ៉ាក់សាំងការពារជំងឺរើមរួមគ្នា។ ការឡើងក្រហម និងហើមក៏អាចកើតមាននៅកន្លែងចាក់ថ្នាំផងដែរ។
- អការៈអស់កម្លាំង ឈឺសាច់ដុំ ឈឺក្បាល ញ័រ គ្រុនក្តៅ ឈឺក្រពះ និងចង្អោរ ជារឿងធម្មតាបន្ទាប់ពីចាក់វ៉ាក់សាំងការពារជំងឺរើមរួមគ្នា។

ផលរំខានទាំងនេះអាចរំខានជាបណ្តោះអាសន្នដល់ការធ្វើសកម្មភាពប្រចាំរបស់ អ្នកទទួលថ្នាំវ៉ាក់សាំង។ រោគសញ្ញាបាត់ទៅវិញដោយខ្លួនឯងក្នុងរយៈពេល 2 ទៅ 3 ថ្ងៃ។ អ្នកនៅតែអាចចាក់វ៉ាក់សាំជំងឺរើមរួមគ្នាជាដូសទីពីរបាន ទោះបីជាអ្នកមានប្រតិកម្មក្រោយពេលចាក់ដូសដំបូងក៏ដោយ។

Guillain-Barré Syndrome (GBS) ជំងឺប្រព័ន្ធប្រសាទធ្ងន់ធ្ងរ ត្រូវបានគេរាយការណ៍ថាកម្រមានណាស់ បន្ទាប់ពីវ៉ាក់សាំងហ្សូសទ័ររួមគ្នា។

ពេលខ្លះ មនុស្សសន្លប់ បន្ទាប់ពីដំណើរការវេជ្ជសាស្ត្ររួមទាំងការចាក់ថ្នាំវ៉ាក់សាំង។ សូមប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក ប្រសិនបើលោកអ្នកវិលមុខ ឬចក្ខុញ្ញាណផ្លាស់ប្តូរ ឬឮសំឡេងហឹងក្នុងត្រចៀក។

ដូចថ្នាំផ្សេងទៀតដែរ ថ្នាំវ៉ាក់សាំងកម្រនឹងបង្កប្រតិកម្មអាលែហ្ស៊ីធ្ងន់ធ្ងរ បួសធ្ងន់ធ្ងរផ្សេង ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតណាស់។

## 5. ចុះបើមានបញ្ហាធ្ងន់ធ្ងរ?

ប្រតិកម្មអាលែហ្ស៊ីអាចកើតឡើងបន្ទាប់ពីអ្នកទទួលថ្នាំបង្ការចាកចេញពីគ្លីនិក ប្រសិនបើអ្នកឃើញសញ្ញានៃប្រតិកម្មអាឡែហ្សីធ្ងន់ធ្ងរ (កន្ទួលក្រហម ហើមមុខ ហើមបំពង់ក ពិបាកដកដង្ហើម ឬចង្វាក់ បេះដូងញាប់ វិលមុខ ឬខ្សោយ) សូមទូរស័ព្ទទៅលេខ **9-1-1** ហើយបញ្ជូន អ្នកជំងឺទៅមន្ទីពេទ្យដែលជិតបំផុត។

សម្រាប់សញ្ញាផ្សេងទៀតដែលធ្វើឱ្យអ្នកបារម្ភ សូមទូរស័ព្ទទៅអ្នកផ្តល់សេវា ថែទាំសុខភាពរបស់អ្នក។

ប្រតិកម្មទៅប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំងគួរតែត្រូវបានរាយការណ៍ទៅ Vaccine Adverse Event Reporting System (VAERS)។ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកជាធម្មតានឹងដាក់របាយការណ៍នេះ ឬអ្នកអាចធ្វើវាដោយខ្លួនឯងបាន។ សូមចូលទៅគេហទំព័រប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង (VAERS) www.vaers.hhs.gov ឬទូរស័ព្ទទៅលេខ **1-800-822-7967**។ *ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង(VAERS) សម្រាប់តែការរាយការណ៍ប្រតិកម្មប៉ុណ្ណោះ។ សមាជិកបុគ្គលិករបស់ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង (VAERS) មិនផ្តល់ដំបូន្មានផ្នែកវេជ្ជសាស្ត្រទេ។*

## 6. តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ មូលដ្ឋានរបស់លោកអ្នក។
- សូមចូលទៅ ឬនៅFood and Drug Administration (គេហទំព័ររដ្ឋបាលអាហារនិងឱសថ (FDA)) ដើម្បីទទួលបានកញ្ចប់សេវាកម្មថ្នាំបង្ការ និងព័ត៌មានបន្ថែម www.fda.gov/vaccines-blood-biologics/vaccines។
- Centers for Disease Control and Prevention (សូមទាក់ទងមជ្ឈមណ្ឌលទប់ស្កាត់ និងបង្ការជំងឺ (CDC)) ៖
  - សូមទូរស័ព្ទទៅលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលមើលគេហទំព័ររបស់ CDC នៅ www.cdc.gov/vaccines។

Khmer translation provided by Immunize.org